# របាយការណ៍កិច្ចប្រជុំ

# ស្តីពី

# ការត្រួតពិនិត្យ ការគ្រប់គ្រងសកម្មភាព និងថវិកាឆ្នាំ២០១៤

# និងលើកទិសដៅបន្ត

# ដោយឯកឧត្តម ជាម ប៉េអា

## សូមគោរព ឯកឧត្តម ង៉ាន់ ចំរើន អនុប្រធានប្រតិបត្តិនៃលេខាធិការដ្ឋាន គ.ជ.អ.ប

ក្នុងឱកាសនេះ ខ្ញុំបាទមានកិត្តិយស សូមធ្វើសេចក្តីរាយការណ៍ ជូនអង្គប្រជុំ និងឯកឧត្តមប្រធានជ្រាប អំពីលទ្ធផលនៃកិច្ចប្រជុំនេះ ដូចតទៅ៖

ដូចឯកឧត្តម លោកជំទាវ អស់លោក លោកស្រី បាន ជ្រាបហើយថា កិច្ចប្រជុំរបស់យើង បានរៀបចំឡើងរយៈពេល០៣ ថ្ងៃ គឺចាប់ពីថ្ងៃទី ០៧-០៩ ខែកក្កដា ឆ្នាំ២០១៤ នៅសាលប្រជុំក្រសួងមហាផ្ទៃ ដោយអង្គភាពទាំង៤ នៃលេខាធិការដ្ឋាន គ.ជ.អ.ប។ សមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះរួមមាន៖

- តំណាងអនុកម្មវិធីទាំង៥ ចំនួន ១៥ រូប
- នាយករដ្ឋបាលរាជធានី ខេត្ត ចំនួន ២៥រូប
- ទីប្រឹក្សាគ្រប់គ្រងកម្មវិធីខេត្ត ចំនួន ២៤ រូប
- ទីប្រឹក្សាហិរញ្ញវត្ថុរាជធានី ខេត្ត ចំនួន ២៤ រូប
- មន្ត្រីហិរញ្ញវត្ថុខេត្ត ចំនួន ២៤ រូប
- មន្ត្រីទទួលបន្ទុកបញ្ចូលNAD ចំនួន ២៤ រូប
- ក្រុមការងារនៃអង្គភាពទាំង៤ ចំនួន ៣៦ រូប

**សរុបចំនួន ១៧៣ រូប ដែលបានចូលរួមកិច្ចប្រជុំនេះ**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមរំលឹកជូន អង្គប្រជុំ ផងដែរដល់ គោលបំណងសំខាន់នៃកិច្ចប្រជុំរបស់យើងគឺ៖

- តាមដាននូវការរីកចម្រើននៃការអនុវត្តផែនការពន្យាពេល០១ឆ្នាំនៃផអ៣។
- ការគ្រប់គ្រងថវិកានៃ ផសថឆ្នាំ២០១៤ និងពិភាក្សាអំពីបញ្ហាប្រឈមនានា។
- ការពង្រឹងប្រព័ន្ធNADនិងនីតិវិធីធ្វើវិសោធនកម្មសេចក្តីសម្រេចរួម។
- កំណត់ឲ្យបាននូវបញ្ហាដែលអនុវត្តកន្លងមក និងលើកទិសដៅបន្ត។

អង្គប្រជុំ មានកិត្តិយស ដោយបានការចូលរួមបើកអង្គប្រជុំ ឯកឧត្តម ង៉ាន់ ចំរើន អនុប្រធានប្រតិបត្តិលេខាធិការដ្ឋានគ.ជ.អ.ប ដែលបានឧទ្ទេសនាមជូនអង្គប្រជុំអំពីដំណើរការវិវឌ្ឍន៍ចុងក្រោយនៃដំណើរការអនុវត្តកម្មវិធីជាតិរយៈពេល១០ សម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលក្នុងនោះយើងបានជួប រួមមានបញ្ហាប្រឈមក្នុងការអនុវត្តមូលនិធិក្រុង ស្រុក ជួបការលំបាកក្នុងការផ្ទេរមុខងារដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ការខិតខំដោះស្រាយបញ្ហាធនធានមនុស្ស និងការកសាងសមត្ថភាពមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ និងការវិវត្តន៍នៃដំណើរការនៃការ

រៀបចំតាក់តែងផអ៣ដំណាក់កាលទី០២។ អង្គប្រជុំ ក៏បានទទួលនូវអនុសាសន៍ណែនាំ របស់ឯកឧត្តមផងដែរឲ្យមានការពិភាក្សាផ្តោតខ្លាំងទៅលើអាទិភាពទាំង១៣ ដែលអនុកម្មវិធីទាំងអស់បានព្រមព្រៀងគ្នាអនុវត្តសម្រេចឲ្យបានក្នុងឆ្នាំ២០១៤នេះ ។ ឯកឧត្តមអនុប្រធានប្រតិបត្តិ ក៏បានណែនាំឲ្យអង្គភាពត្រួតពិនិត្យនិងវាយតម្លៃនៃលេខាធិការដ្ឋានគ.ជ.អ.ប ពិនិត្យលទ្ធភាពក្នុងរៀបចំប្រព័ន្ធVideo Conference ដើម្បីអាចឲ្យថ្នាក់ដឹកនាំលេខាធិការដ្ឋានគ.ជ.អ.ប អាចរៀបចំកិច្ចប្រជុំតាមប្រព័ន្ធនេះជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រោះថា កិច្ចប្រជុំបែបនេះ អាចជួយកាត់បន្ថយការចំណាយក្នុងការធ្វើដំណើរបានជាច្រើន។

បន្ទាប់ពីមតិស្វាគមន៍ អង្គប្រជុំបានដំណើរការជាបន្តបន្ទាប់ ដូចតទៅ៖

1. បទបង្ហាញអំពីលទ្ធផលរីកចម្រើននៃការអនុវត្តសម្រេចបានរបស់អនុកម្មវិធីទាំង៦។
2. បទបង្ហាញអំពីលទ្ធផលរីកចម្រើននៃការអនុវត្តសម្រេចបានរបស់រាជធានីខេត្តទាំង២៤។
3. ការពិភាក្សាអំពីបញ្ហាប្រឈមនានា នៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ។
4. បទបង្ហាញអំពីការធ្វើសោធនកម្មសេចក្តីសម្រេចរួម និងពេលវេលានិងនីតិវិធីនានា។
5. បទបង្ហាញអំពីវឌ្ឍនភាពនិងបញ្ហាប្រឈមអង្គភាពវិភាគនិងអភិវឌ្ឍន៍គោលនយោបាយ។
6. បទបង្ហាញរបស់អង្គភាពរដ្ឋបាលនិងហិរញ្ញវត្ថុអំពីបញ្ហាមួយចំនួនរកឃើញដោយសវនករ។

អង្គប្រជុំទាំងមូល បានលើកឡើងនូវបញ្ហាប្រឈមមួយចំនួន ដែលស្នើសុំលេខាធិការដ្ឋាន ជួយសម្រប សម្រួលដូចជា៖

1. ការដែលគ.ជ.អ.ប មិនបានប្រជុំទៀតទាត់ ធ្វើឱ្យមានការចេញ លិខិតបទដ្ឋាន សម្រាប់ឱ្យថ្នាក់ក្រោមជាតិ អនុវត្តមិនមានសង្គតិភាព ពាក់ព័ន្ធទៅនិងការកសាងថវិកា ការអនុវត្តមូលនិធិក្រុងស្រុក ការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគ ជាដើម ដូចជា អនុក្រិត្យលេខ អនក្រ១៧២ សេចក្តីជូនដំណឹង លេខ សជណ០១៥ និងសារាចរណែនាំលេខ ០០៧ គឺមិនមានសង្គតិភាពគ្នាទាល់តែសោះ។ សមាជិកអង្គប្រជុំយល់ថា ការមិនបានប្រជុំទៀងទាត់ នាំឱ្យគ.ជ.អ.ប ខ្វះព័ត៌មាន សម្រាប់ជំរុញការអនុវត្តឱ្យបាន សម្រេចតាមផែនការគ្រោង។
2. ទាក់ទងនឹងសូចនាករអនុវត្តមូលនិធិក្រុងស្រុក ឱ្យបាន៨០% ដល់ដំណាច់ឆ្នាំ២០១៤ អង្គប្រជុំយល់ថា ប្រហែលជាមិនអាចទៅរួចទេ ដោយសារតែ៖
   - យន្តការគាំទ្រ ការអនុវត្តមូលនិធិក្រុងស្រុក ដំណើរការមិនទាន់ល្អ។
   - ការរៀបចំគម្រោងនិងថវិកាក្រុងស្រុក មិនទៅតាមគោលការណ៍ណែនាំ។
   - អង្គភាពលទ្ធកម្មមិនដំណើរការ ដោយត្រូវរង់ចាំការអនុម័តយ៉ាងយូរ ពីថ្នាក់ជាតិ។
   - ខ្វះធនធានមនុស្ស នៅថ្នាក់ស្រុក ទន្ទឹមនឹងនោះ ការជ្រើសរើសDITA និងDSO ត្រូវរង់ចាំការសម្រេចពីHR របស់លេខាធិការដ្ឋានយូរពេក។
   - ការតម្រូវឱ្យស្រុកឡើងមក ទាក់ទងផ្ទាល់ជាមួយក្រសួង គឺបានបង្កការលំបាកខ្លាំង ដល់ថ្នាក់ស្រុក។
   - ថវិកា ក្រុងស្រុកអនុម័តដោយក្រុមប្រឹក្សារួចហើយ ប៉ុន្តែក្រសួងMEFត្រូវធ្វើអនុលោមភាព ហើយមិនផ្តល់ដំណឹងទៅក្រុងស្រុកវិញ
3. ភាពមិនស៊ីសង្វាក់គ្នានៃប្រព័ន្ធកសាងផែនការ ដែលធ្វើឱ្យថ្នាក់ក្រោមជាតិ ជួបការលំបាក មិនដឹងពិតប្រាកដថាត្រូវអនុវត្តតាមការណែនាំរបស់ក្រសួងមហាផ្ទៃ ដែលបណ្តុះបណ្តាលក្រោមគម្រោងPILACII ឬការណែនាំរបស់ក្រសួងផែនការ តាមរយៈមន្ទីរផែនការខេត្ត ។

4. ការជ្រើសរើសទីប្រឹក្សាបច្ចេកទេស ដោយលេខាធិការដ្ឋាន មានភាពយឺតយ៉ាវធ្វើឱ្យការរៀបចំ ប្រព័ន្ធត្រួតពិនិត្យមើលពីលើឬអធិការកិច្ច ក៏យឺតយ៉ាវដែរ។
5. ក្រៅពីនោះ រាជធានីខេត្ត បានស្នើសុំ ការជម្រុញយ៉ាងណាឱ្យសេចក្តីសម្រេចរួម បានអនុម័តយ៉ាងយូរត្រឹមចុងខែមករា រៀងរាល់ឆ្នាំ។ ម៉្យាងទៀត ភាពយឺតយ៉ាវ របស់ថ្នាក់ក្រោមជាតិគឺជាប់ពាក់ព័ន្ធភាគច្រើន ដល់ការរង់ចាំ ការបណ្តុះបណ្តាល ពីថ្នាក់ជាតិ។
6. ខេត្តនៅប្រើប្រាស់ឧបករណ៍ចាស់ៗ ដែលសល់ពីគម្រោងមុនៗ ដូចជា រថយន្ត ម៉ូតូ កុំព្យូទ័រ ម៉ាស៊ីនហ្វូតូ ម៉ាស៊ីនបញ្ចាំងស្លាយ ។ល។ ហេតុនេះ សូមស្នើពិនិត្យលទ្ធភាពឡើងវិញ ដោយផ្តល់ការគាំទ្របន្ថែម ជាការជួសជុល ការថែរក្សា និងលុបចោលពីបញ្ជីសារពើភណ្ឌនូវសម្ភារៈមិនអាចប្រើប្រាស់បាន ។
7. ស្នើសុំផ្តល់លទ្ធភាពឱ្យខេត្តអនុវត្តលទ្ធកម្មតូចតាចខ្លះផង (Computer, Printer, etc.)។
8. សុំស្នើសុំជួយជម្រុញកិច្ចលទ្ធកម្មសម្ភារៈ សម្រាប់បុគ្គលិកសម្របសម្រួលក្រុមប្រឹក្សា។
9. ស្នើសុំ ធ្វើប្រតិភូកម្មទៅថ្នាក់ក្រោមជាតិ អំពីលទ្ធកម្មកង់ឡាន ដើម្បីបង្កលក្ខណៈងាយស្រួល។
10. ស្នើសុំ លេខាធិការដ្ឋានគ.ជ.អ.ប ជួយផ្តល់បញ្ជីឈ្មោះ ជនបង្គោលទទួលបន្ទុកគាំទ្របច្ចេកទេស នៅថ្នាក់ជាតិទាក់ទងនឹង PID, District Finance, CS Accountability។
11. ស្នើសុំមានការបញ្ជាក់ច្បាស់លាស់អំពីបញ្ហាយឺតយ៉ាវនៃសេវាធានារ៉ាប់រងសុខភាព។

**ករណីពិសេសសម្រាប់ខេត្តត្បូងឃ្មុំ**

- ស្នើសុំការគាំទ្រការរៀបចំសិក្ខាសាលាតម្រង់ទិស សម្រាប់ក្រុមប្រឹក្សានិងគណៈអភិបាល ទីចាត់ការទាំងអស់។
- ស្នើសុំការគាំទ្រ កសាងប្រព័ន្ធទំនាក់ទំនងព័ត៌មានវិទ្យា Internet, email។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម មេត្តាជួយផ្តល់អនុសាសន៍ណែនាំ ជូនសមាជិកអង្គប្រជុំតាមការគួរ។

សូមគោរពជូនពរ .................។

សូមអរគុណ

# ស្ថានភាពនៃការអនុវត្តសម្រេចបានសូចនាករអាទិភាពនាំង១៣ នៃផអ៣ និងសំណូមពរនានា

| អាទិភាព | សូចនាករអនុវត្ត | ពេលវេលា | លទ្ធផល | អនុកម្មវិធី | មូលហេតុ/បញ្ហាចោទ | សំណូមពរ/ការព្រមព្រៀង |
|---|---|---|---|---|---|---|
| ១.ការពង្រឹង ការគ្រប់គ្រងការអនុវត្តកម្មវិធី | ១-ពិនិត្យឡើងវិញនូវតួនាទី ភារកិច្ចរបស់គ.ជ.អ.បនិងអនុ.កម្មការ | ត្រី.ទី១ | ☹ | អនុ.ទី១ | ដោយសារ មានការផ្លាស់ប្តូរសមាសភាពមន្ត្រីនៅតាមក្រសួងពាក់ព័ន្ធមួយចំនួន | ស្នើជំរុញអនុវត្តឱ្យបានក្នុងត្រីមាសទី៣ |
| | ២-កិច្ចប្រជុំប្រចាំត្រីមាស បានរៀបចំទៀងទាត់ របៀបវារៈច្បាស់លាស់ | ត្រី.ទី៤ | ? | អនុ.ទី១ | ការដែលគ.ជ.អ.ប មិនបានប្រជុំទៀតទាត់ធ្វើឱ្យ មានការចេញ លិខិតបទដ្ឋាន សម្រាប់ឱ្យថ្នាក់ក្រោមជាតិ អនុវត្តមិនមានសង្គតិភាពពាក់ព័ន្ធនិង ការកសាងថវិកា អនុវត្តមូលនិធិក្រុងស្រុក ការកសាងផែនការ អភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ។ | ស្នើសុំ លើកយកបញ្ហាមិនប្រក្រតីក្នុងការចេញលិខិតបទដ្ឋាន ទៅថ្នាក់ក្រោមជាតិទៅពិភាក្សា ក្នុងកិច្ចប្រជុំគ.ជ.អ.បៈ<br>- ការអនុវត្តមូលនិធិក្រុងស្រុក<br>- ការរៀបចំថវិកា<br>- ការរៀបចំគម្រោង<br>- ការកសាងផែនការអភិវឌ្ឍ៥ឆ្នាំ និងកម្មវិធីវិនិយោគ |
| | ៣- កិច្ចប្រជុំគ.ជ.អ.ប ចំនួន២ដង បានរាយការណ៍អំពីវឌ្ឍនៈភាព | ត្រី.ទី៤ | ? | អនុ.ទី១ | ការមិនបានអនុវត្ត នាំឱ្យគ.ជ.អ.ប ខ្វះព័ត៌មាន សម្រាប់ជំរុញការអនុវត្តឱ្យបានសម្រេចតាមផែនការគ្រោង។ | ស្នើជំរុញ ការអនុវត្ត ចាប់ពីត្រីមាសទី៣តទៅ។ |
| ២.ការអនុវត្តមូលនិធិក្រុង ស្រុក | ១-បណ្តុះបណ្តាលប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ គ្រប់ក្រុង ស្រុកទាំងអស់ | ត្រី.ទី១ | ☹ | អនុ.ទី៤ | - ដោយសារតែ ប្រភពថវិកាសម្រាប់គាំទ្រមិនច្បាស់លាស់។<br>- ខេត្តរង់ចាំការបណ្តុះបណ្តាលពីថ្នាក់ជាតិ | - SP4 ស្នើសុំADB ឬដអពផ្តល់ថវិកាបានលឿន<br>- រាជធានីខេត្តអាចធ្វើការបណ្តុះបណ្តាលតាមសារាចរណែនាំលេខ ០០៧ ដោយមិនរង់ចាំTOTពីថ្នាក់ឡើយ |
| | ២-ពិនិត្យនិងវាយតម្លៃ ប្រព័ន្ធនិងនីតិវិធីហិរញ្ញវត្ថុក្រុង ស្រុក | ត្រី.ទី៣ | ⚐ | អនុ.ទី៤ | ការចុះតាមដានរបស់ថ្នាក់ជាតិ ពុំបានសហការជាមួយរដ្ឋបាលខេត្ត | ស្នើសុំបង្កើនកិច្ចសហការល្អ ជាមួយ រដ្ឋបាលខេត្ត។ |

សញ្ញាសំគាល់៖ ☺ = បានអនុវត្តតាមផែនការគ្រោង ☹ =មិនបានអនុវត្ត 😐 =អនុវត្តបានខ្លះ កំពុងប្រឹងប្រែងបន្ត ⚐ =អាទិភាពក្នុងត្រីមាសបន្ទាប់ ?= អាចអនុវត្តបានឬទេ ក្នុងត្រីមាសទី៤?

| | | | | | | |
|---|---|---|---|---|---|---|
| | ៣-ការកែសម្រួលសេចក្តីណែនាំនានាតាមការចាំបាច់ | ត្រី.ទី៤ | ? | អនុ.ទី៤ | ហាក់ពុំមានភាពច្បាស់លាស់ ថាតើត្រូវអនុវត្តតាមមូលនិធិក្រុង ស្រុក អនក្រ១៧២ ឬ សជណ០១៥ និងសារាចរណ៍០០៧ ដែលមិនមានសង្គតិភាពគ្នាទាល់តែសោះ។ | ស្នើសុំលើកយកទៅពិភាក្សាក្នុងកិច្ចប្រជុំ គ.ជ.អ.ប និងចេញគោលការណ៍ណែនាំរួមមួយ ដែលថ្នាក់ក្រោមជាតិអាចអនុវត្តតាមបាន។ |
| | ៤-មូលនិធិក្រុងស្រុក៨0%ត្រូវបានប្រើប្រាស់ | ត្រី.ទី៤ | ? | អនុ.ទី៤ | ប្រហែលជាមិនអាចអនុវត្តបាន ដោយសារមាន ភាពមិនស៊ីសង្វាក់គ្នា ផ្នែកគោលការណ៍ណែនាំ ដូចជា៖<br>- យន្តការគាំទ្រ ការអនុវត្តមូលនិធិក្រុងស្រុក ដំណើរការមិនទាន់ល្អ<br>- ការរៀបចំគម្រោងនិងថវិកាក្រុងស្រុក មិនទៅតាមគោលការណ៍ណែនាំ<br>- អង្គភាពលទ្ធកម្មមិនដំណើរការ ដោយត្រូវរង់ចាំការអនុម័តយូរ ពីថ្នាក់ជាតិ<br>- ខ្វះធនធានមនុស្ស នៅថ្នាក់ស្រុក<br>- មន្ត្រីគាំទ្រ មិនទាន់បានជ្រើសរើស រង់ចាំការសម្រេចពីHRរបស់លេខាធិការដ្ឋាន<br>- ការតម្រូវស្រុកឡើងមក ទាក់ទងផ្ទាល់ជាមួយក្រសួង គឺបានបង្កការលំបាកខ្លាំងដល់ថ្នាក់ស្រុក។<br>- ថវិកា ក្រុងស្រុកអនុម័តដោយក្រុមប្រឹក្សាហើយ ប៉ុន្តែក្រសួងMEFត្រូវធ្វើអនុលោមភាព ហើយមិនផ្តល់ដំណឹងទៅក្រុងស្រុកវិញ | - ស្នើសុំជម្រុញ ឱ្យមានការសម្រេចចិត្តនានា ដោយថ្នាក់ជាតិ ឱ្យបានក្នុងត្រីមាសទី៣ ដើម្បីថ្នាក់ក្រោមជាតិ អាចអនុវត្ត បានខ្លះ នៅត្រីមាសទី៤។<br>- ស្នើសុំលើកយកបញ្ហា ទាំងអស់នេះទៅពិភាក្សា នៅក្នុងកិច្ចប្រជុំគ.ជ.អ.ប និងចេញគោលការណ៍ណែនាំ ឱ្យបានច្បាស់លាស់ ងាយស្រួលអនុវត្តតាម។<br>- ស្នើសុំ ផ្តល់ការណែនាំ ដល់ក្រុងស្រុកស្តីពីការអនុវត្តមូលនិធិ Sida រួមទាំងនីតិវិធីរៀបចំ និងអនុវត្ត ឱ្យបានលឿនបំផុតតាមអាចធ្វើទៅបាន។ |

សញ្ញាសំគាល់៖ ☺ = បានអនុវត្តតាមផែនការគ្រោង ☹ =មិនបានអនុវត្ត 😐 =អនុវត្តបានខ្លះ កំពុងប្រឹងប្រែងបន្ត ⚐ =អាទិភាពក្នុងត្រីមាសបន្ទាប់ ?= អាចអនុវត្តបានឬទេ ក្នុងត្រីមាសទី៤?

| | | | | | | |
|---|---|---|---|---|---|---|
| ៣.ប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ | ១- ឯកសារគោលនយោបាយ ចំណូលផ្ទាល់បានអនុម័ត | ត្រី.ទី២ | ☹ | អនុ.ទី៤ | ការជួលក្រុមហ៊ុនទីប្រឹក្សាដំណើរការទៅយឺត។ តាមនីតិវិធីរបស់ADB ។ | ស្នើសុំការពិភាក្សាជាមួយ ADB ដើម្បីជំរុញឱ្យអាចដំណើរការបាន នៅត្រីមាសបន្ទាប់ ។ |
| | ២-សូចនាករ "ចំណូលផ្ទាល់/ថវិកា" បានឯកភាពសម្រាប់ឆ្នាំ២០១៥-១៨ | ត្រី.ទី២ | 😐 | អនុ.ទី៤ | ការជួលក្រុមហ៊ុនទីប្រឹក្សា ដំណើរការទៅយឺត តាមនីតិវិធីរបស់ADB ។ | ស្នើសុំការពិភាក្សាជាមួយ ADB ដើម្បីជំរុញឱ្យអាចដំណើរការបាន ។ |
| | ៣-ការអនុវត្តសាកល្បង លើការប្រមូល និងការគ្រប់គ្រងចំណូលផ្ទាល់ | ត្រី.ទី៣ | ⚐ | អនុ.ទី៤ | ពុំមានការពិភាក្សា រង់ចាំសកម្មភាពខាងលើសិនទើបអាចអនុវត្តបាន ។ | រង់ចាំពិនិត្យមើលលទ្ធផលក្នុង ត្រីមាសទី៣ |
| | ៤-វាយតម្លៃការសាកល្បង ការប្រមូលចំណូលផ្ទាល់ សម្រាប់បន្ត២០១៥ | ត្រី.ទី៤ | ? | អនុ.ទី៤ | បើសកម្មភាពខាងលើមិនអាចអនុវត្តបាន សកម្មភាពនេះ ក៏មិនអាចអនុវត្តបានដែរ | |
| ៤. ការផ្ទេរមុខងារ | ១-លិខិតបទដ្ឋាននានាអំពីមុខងារជាជម្រើស បានរៀបចំនិងអនុម័ត | ត្រី.ទី២ | 😐 | អនុ.ទី១ | ទើបតែបានរៀបចំ មិនទាន់បានអនុម័តនៅឡើយ | ទោះបីយឺត តែនៅតែអាចបញ្ចប់នៅត្រីមាសទី៣ |
| | ២-ដំណើរការផ្ទេរមុខងារ និងលិខិតបទដ្ឋានត្រូវបានពិនិត្យមើលឡើងវិញ | ត្រី.ទី២ | 😐 | អនុ.ទី១ | សន្យានឹងបង្កើនល្បឿន អនុវត្តការងារ | ទោះបីយឺត តែនៅតែអាចបញ្ចប់នៅត្រីមាសទី៣ |
| | ៣-ចំណុចដៅSMART នៃការផ្ទេរមុខងារឆ្នាំ ២០១៥-១៨ បានឯកភាព | ត្រី.ទី២ | ☹ | អនុ.ទី១ | សូចនាករនេះ មិនមានភាពច្បាស់លាស់ | ស្នើសុំការបំភ្លឺបន្ថែម អំពីទីប្រឹក្សាជំនាញ |
| | ៤-អនុវត្ត និងវាយតម្លៃ ការសាកល្បងមុខងារពីរះសុខភាពនិងអនាម័យ | ត្រី.ទី៣ | ⚐ | អនុ.ទី១ | អាចបញ្ចប់នៅត្រីមាសទី៣ | រង់ចាំមើលការអនុវត្តនៅត្រីមាសទី០៣ |
| | ៥-ផែនការសាកល្បងផ្ទេរមុខងារទាំងនេះបានរៀបចំសម្រាប់ឆ្នាំ២០១៥ | ត្រី.ទី៤ | ? | អនុ.ទី១ | អាចបញ្ចប់បាននៅត្រីមាសទី៤ | នឹងអនុវត្តបាននៅត្រីមាសទី០៤ ទៅតាមផែនការគ្រោង |
| ៥.គណនេយ្យភាពសង្គម | ១-សាកល្បងអំពីI4Cs និងប័ណ្ណដាក់ពិន្ទុរបស់ប្រជាពលរដ្ឋ | ត្រី.ទី១ | 😐 | អនុ.ទី១ | -មិនទាន់ព្រមព្រៀងគ្នាជាមួយ ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល អំពីI4Csនៅឡើយ ។ | បន្តជម្រុញ ការអនុវត្តនៅត្រីមាសទី៣ ដោយមានការផ្តល់ថវិកាដល់ថ្នាក់ស្រុក |
| | ២-សេចក្តីណែនាំនិងសៀវភៅណែនាំសម្រាប់អនុវត្តត្រូវបានរៀបចំបញ្ចប់ | ត្រី.ទី២ | 😐 | អនុ.ទី១ | -បានតែសេចក្តីព្រាងប៉ុណ្ណោះ មិនទាន់បានដាក់ ជូនពិនិត្យនិងអនុម័តនៅឡើយ ។ | បន្តជម្រុញ ការអនុវត្តនៅត្រីមាសទី៣ តាមថវិកា ដែលគ្រោងវិភាជន៍សម្រាប់ |

សញ្ញាសំគាល់៖ ☺ = បានអនុវត្តតាមផែនការគ្រោង ☹ =មិនបានអនុវត្ត 😐 =អនុវត្តបានខ្លះ កំពុងប្រឹងប្រែងបន្ត ⚐ =អាទិភាពក្នុងត្រីមាសបន្ទាប់ ?= អាចអនុវត្តបានឬទេ ក្នុងត្រីមាសទី៤?

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | ថ្នាក់ស្រុក ។ |
| | ៣- គ្រប់ឃុំក្នុងស្រុកគោលដៅទាំង២០ មានបិទផ្សាយព័ត៌មានជាសាធារណៈ | ត្រី.ទី៤ | ? | អនុ.ទី១ | -ការអនុម័ត គោលការណ៍ណែនាំ អាចយឺតយ៉ាវ | ជម្រុញការអនុវត្តសាកល្បង តាមគោលការណ៍ណែនាំ ដែលបានព្រាង |
| ៦.លក្ខន្តិកៈដោយឡែក សម្រាប់បុគ្គលិក រដ្ឋបាលថ្នាក់ក្រោមជាតិ | ១- លក្ខន្តិកៈដោយឡែក បានរៀបចំបញ្ចប់ និងអនុម័ត | ត្រី.ទី១ | 😐 | អនុ.ទី៣ | -រង់ចាំគោលការណ៍រួមស្តីពីការរៀបចំមុខងារសាធារណៈរបស់រដ្ឋ<br>- ការអនុម័តយឺត មានផលប៉ះពាល់ដល់ថ្នាក់ក្រោមជាតិ ចំពោះ ការលើកទឹកចិត្តដល់មន្ត្រីត្រូវបំពេញ ការងារ នៅស្រុកជនបទ ដែលបច្ចុប្បន្នកំពុងជួបប្រទះបញ្ហាខ្លាំង | ស្នើជម្រុញឱ្យលឿនក្នុងត្រីមាសទី០៣ |
| | ២- យន្តការគាំទ្រការអនុវត្តលក្ខន្តិកៈនេះត្រូវបានរៀបចំ | ត្រី.ទី២ | 😐 | អនុ.ទី៣ | -មិនអាចអនុវត្តបាន ប្រសិនបើ លក្ខន្តិកៈដោយឡែក មិនអនុម័តទាន់ពេល ។<br>-មានអនុក្រិត្យលេខ៤៩៧ តែមន្ទីរផ្សេងៗថ្នាក់ក្រោមជាតិមិនអាចអនុវត្តបាន ដោយត្រូវនៅរង់ចាំការណែនាំលំអិត | ស្នើលើកយកទៅបន្តនៅត្រីមាសទី៤<br>-ស្នើសុំក្រសួងមហាផ្ទៃ និងមុខងារសាធារណៈ ចេញសេចក្តីណែនាំឱ្យបានឆាប់ |
| | ៣-ប្រព័ន្ធព័ត៌មានHR សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និងផ្សព្វផ្សាយ | ត្រី.ទី៤ | ? | អនុ.ទី៣ | ប្រហែលជាមិនអាចអនុវត្តបាន ដោយសារតែមិនទាន់មានប្រភពថវិកា ឧបករណ៍ និង TA គ្រប់គ្រាន់ | ស្នើសុំថវិកាបន្ថែម ដើម្បីអាចអនុវត្តបាននៅត្រីមាសទី០៤ |
| ៧. យុទ្ធសាស្ត្រ ពង្រឹងតួនាទី និងអំណាចក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ | ១- ពិនិត្យនិងវាយតម្លៃ ការធ្វើសេចក្តីសម្រេចចិត្ត+វិធីសាស្ត្រប្រឹក្សាយោបល់ | ត្រី.ទី២ | 😐 | អនុ.ទី១ | មិនអនុវត្ត ដោយសារពេលវេលា មិនគ្រប់គ្រាន់ | ស្នើសុំអនុវត្តនៅត្រីមាសទី៣ |
| | ២-សេចក្តីព្រាងនៃវិធានផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុកត្រូវបានរៀបចំបញ្ចប់ | ត្រី.ទី២ | 😐 | អនុ.ទី១ | មិនអនុវត្ត ដោយសារពេលវេលា មិនគ្រប់គ្រាន់ | ស្នើសុំអនុវត្តនៅត្រីមាសទី៣ |
| | ៣-យុទ្ធសាស្ត្រអំពីការពង្រឹងតួនាទី និងសិទ្ធិអំណាច បានរៀបចំនិងអនុម័ត | ត្រី.ទី២ | ☹ | អនុ.ទី១ | មិនអនុវត្ត ដោយសារពេលវេលា មិនគ្រប់គ្រាន់ | ស្នើសុំអនុវត្តនៅត្រីមាសទី៣ |

សញ្ញាសំគាល់៖ ☺ = បានអនុវត្តតាមផែនការគ្រោង ☹ =មិនបានអនុវត្ត 😐 =អនុវត្តបានខ្លះ កំពុងប្រឹងប្រែងបន្ត ⚐ =អាទិភាពក្នុងត្រីមាសបន្ទាប់ ?= អាចអនុវត្តបានឬទេ ក្នុងត្រីមាសទី៤?

| | | | | | | |
|---|---|---|---|---|---|---|
| | ៤-សកម្មភាពនានាដែលបានកំណត់ក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រត្រូវបានអនុវត្ត | ត្រី.ទី៤ | ? | អនុ.ទី១ | | ជម្រុញបន្ថែមនៅត្រីមាសទី៤ |
| ៨.ការរៀបចំប្រព័ន្ធកសាងផែនការនិងថវិកាសម្រាប់ប្រភេទផ្សេង គ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិ | ១-សេចក្តីព្រាងគោលនយោបាយបានបញ្ចប់និងអនុម័ត ដោយគ.ជ.អ.ប | ត្រី.ទី១ | 😐 | អនុ.ទី១ | បញ្ចប់រួចហើយ តែពុំមានសកម្មភាព អនុវត្តបន្តទៀតឡើយ | |
| | ២-ការសិក្សា ដើម្បីរៀបចំកិច្ចដំណើរកសាងផែនការនិងថវិកា របស់SNA | ត្រី.ទី២ | ☹ | អនុ.ទី៥ | - ថ្នាក់ក្រោមជាតិ មានការលំបាក មិនដឹងថាតើត្រូវអនុវត្តតាមការណែនាំ ក្រសួងមហាផ្ទៃ ឬក្រសួងផែនការ។<br>- តើអ្វីដែលPILACII កំពុងបណ្តុះបណ្តាលយកជាបានការឬអត់? | -ស្នើសុំអោយក្រសួងទាំង២ ពិភាក្សាគ្នាយកប្រពន្ធ័រួមមួយ (មុននឹងធ្វើការបណ្តុះបណ្តាលទៅខេត្ត។<br>-គួរមានការពិភាក្សា ក្នុងកិច្ចប្រជុំរបស់គ.ជ.អ.ប ឬអនុគណៈកម្មការ។ |
| | ៣-កែសម្រួលសេចក្តីណែនាំពាក់ព័ន្ធការកសាងផែនការនិងរៀបចំថវិកា | ត្រី.ទី២ | ☹ | អនុ.ទី៥ | - អនុកម្មវិធីទី៥ បដិសេធពុំទទួលស្គាល់ និងបញ្ជាក់ថាពុំមានក្នុងផ.ស.ថ ២០១៤ឡើយ។ | ស្នើលើកយកទៅពិភាក្សាក្នុង អង្គប្រជុំ គ.ជ.អ.ប |
| | ៤- សេចក្តីណែនាំទាំងអស់ បានកែសម្រួលបញ្ចប់ | ត្រី.ទី២ | ☹ | អនុ.ទី៥ | -អនុកម្មវិធីទី៥ ពុំបានគ្រោង អនុវត្តឡើយ | ស្នើលើកយកទៅពិភាក្សាក្នុង អង្គប្រជុំ គ.ជ.អ.ប |
| | ៥- បណ្តុះបណ្តាលសេចក្តីណែនាំដែលបានកែសម្រួលទាំងនោះ | ត្រី.ទី៣ | ⚐ | អនុ.ទី៥ និង ទី២ | -បណ្តុះបណ្តាលតាមវិធីសាស្ត្រ របស់ក្រសួងមហាផ្ទៃ តែពុំមានការចូលរួម ឬទទួលស្គាល់ពីក្រសួងផែនការឡើយ (ជារបស់PILACII)<br>-ពេលវេលារៀបចំថវិកា និងពេលវេលារៀបចំផែនការមិនស៊ីសង្វាក់គ្នា | -ស្នើសុំសម្របសម្រួលពីគ.ជ.អ.ប ដើម្បីមានភាពស៊ីសង្វាក់គ្នា រវាងក្រសួងមហាផ្ទៃ និងក្រសួងផែនការ។<br>-អំពីពេលវេលា រៀបចំផែនការ និងថវិកា គួរតែមានភាពស៊ីសង្វាក់គ្នា។ |
| ៩.ការពង្រឹងប្រព័ន្ធត្រួតពិនិត្យមើលពីលើ ឬអធិការកិច្ច | ១-ប្រព័ន្ធ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធត្រូវបានរៀបចំ | ត្រី.ទី២ | 😐 | អនុ.ទី២ | -លេខាធិការដ្ឋាន មានភាពយឺតយ៉ាវក្នុងការជ្រើសរើសទីប្រឹក្សាបច្ចេកទេស ដែលត្រូវរៀបចំប្រព័ន្ធនេះ។<br>-គ្មានអ្នកដាក់ពាក្យ | -ស្នើលេខាធិការដ្ឋាន ជម្រុញការ ជ្រើសរើសទីប្រឹក្សាបច្ចេកទេស<br>-ស្នើបន្តអនុវត្តនៅត្រីមាសទី៣ |
| | ២-ប្រព័ន្ធនេះ បានអនុវត្តសាកល្បង | ត្រី.ទី៣ | ⚐ | អនុ.ទី២ | ប្រហែលជាមិនអាចអនុវត្តបាន ប្រសិនបើ | ស្នើលើកយកទៅអនុវត្តនៅត្រីមាសទី៤ |

សញ្ញាសំគាល់៖ ☺ = បានអនុវត្តតាមផែនការគ្រោង ☹ =មិនបានអនុវត្ត 😐 =អនុវត្តបានខ្លះ កំពុងប្រឹងប្រែងបន្ត ⚐ =អាទិភាពក្នុងត្រីមាសបន្ទាប់ ?= អាចអនុវត្តបានឬទេ ក្នុងត្រីមាសទី៤?

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | មិនអាចជ្រើសរើសទីប្រឹក្សាបាន | |
| | ៣-ប្រព័ន្ធអធិការកិច្ចត្រូវបានវាយតម្លៃ | ត្រី.ទី៤ | ? | អនុ.ទី២ | អាចមិនត្រូវបានអនុវត្ត ដោយសារតែ មិនមានគ្រោងក្នុងផសថ២០១៤។ | ស្នើសុំលេខាធិការដ្ឋាន ពិចារណាថាតើត្រូវធ្វើវិសោធនកម្មផសថឬទេ? |
| ១០. យុទ្ធសាស្ត្រពង្រឹងសមត្ថភាពរដ្ឋបាលរបស់ក្រុង ស្រុក | ១-ថវិកាបានផ្តល់ទៅក្រុងស្រុក ដើម្បីជ្រើសរើសមន្ត្រីកិច្ចសន្យា | ត្រី.ទី១ | 😐 | អនុ.ទី១ | -ខេត្តបានរង់ចាំយ៉ាងយូរ ក្នុងការពិនិត្យបញ្ជីសម្រាំងបេក្ខជន DITA និងមន្ត្រី DSO ពីលេខាធិការដ្ឋាន ។<br>-ពុំមានបេក្ខជនដាក់ពាក្យ ដោយសារ ចំនួនបៀវត្ស មានកម្រិតទាប។ | បើការងារច្រើនហួស គួរប្រគល់កិច្ចការនេះទៅថ្នាក់ក្រោមជាតិ អនុវត្តដោយខ្លួនឯងវិញ។ |
| | ២-សៀវភៅណែនាំស្តីពីកិច្ចប្រតិបត្តិការរបស់រដ្ឋបាលក្រុងស្រុក រៀបចំបញ្ចប់ | ត្រី.ទី២ | 😐 | អនុ.ទី២ | -ថ្នាក់ក្រោមជាតិ មិនអាចអនុវត្តបាន ដោយត្រូវរង់ចាំលិខិតបទដ្ឋានពាក់ព័ន្ធ ដូចជា ៖ការរៀបចំដីកាក្រុមប្រឹក្សា។ | -គ.ជ.អ.ប គួរជម្រុញឱ្យមាន ការរៀបចំគោលការណ៍ណែនាំ ឱ្យបានឿន នៅត្រីមាសទី៣ |
| | ៣-យុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពបានពិនិត្យ និងកែសម្រួល | ត្រី.ទី២ | ☹ | អនុ.ទី១ | ប្រហែលជាមិនអាចសម្រេចបាន ដោយសារតែអង្គភាពគោលនយោបាយ មិនមានភាពច្បាស់លាស់ អំពីថាតើត្រូវអនុវត្តដូចម្តេច។ | -ស្នើសុំការពិភាក្សាផ្ទៃក្នុងបន្ថែម<br>- ខេត្តស្នើសុំវិភាជន៍ថវិកាដល់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានសមស្រប<br>-សំណូមពរឱ្យអភិបាលខេត្តជួយគាំទ្រ |
| ១១.សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | ១-សមាគមក្រុមប្រឹក្សាក្រុង ស្រុក និងឃុំសង្កាត់ដែលបានបង្កើតបានបញ្ចូលគ្នាដើម្បីបង្កើតជាសម្ព័ន្ធភាពជាតិ | ត្រី.ទី១ | 😐 | អនុ.ទី៦ | ត្រូវរង់ចាំមហាសន្និបាត | -សន្យាអនុវត្តនៅត្រីមាសទី៣<br>-មិនគួរអូសបន្លាយយូរពេកទេ |
| | ២-សមាគមក្រុមប្រឹក្សាក្រុងស្រុកខណ្ឌនិងឃុំ សង្កាត់ នៅខេត្តចំនួន១៣ផ្សេងទៀតត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ និង បានបញ្ចូលទៅក្នុងសម្ព័ន្ធភាពជាតិ | ត្រី.ទី២ | 😐 | អនុ.ទី៦ | ត្រូវរង់ចាំមហាសន្និបាត | -សន្យាអនុវត្តនៅត្រីមាសទី៣<br>-មិនគួរអូសបន្លាយយូរពេកទេ |
| | ៣-អគ្គលេខាធិការដ្ឋាន សម្រាប់គាំទ្រសមាគមទាំងពីរ ត្រូវបានរៀបចំឡើង | ត្រី.ទី២ | 😐 | អនុ.ទី៦ | | -សន្យាអនុវត្តបន្តនៅត្រីមាសទី៣<br>-មិនគួរអូសបន្លាយយូរពេកទេ |

សញ្ញាសំគាល់៖ ☺ = បានអនុវត្តតាមផែនការគ្រោង ☹ =មិនបានអនុវត្ត 😐 =អនុវត្តបានខ្លះ កំពុងប្រឹងប្រែងបន្ត ⚐ =អាទិភាពក្នុងត្រីមាសបន្ទាប់ ?= អាចអនុវត្តបានឬទេ ក្នុងត្រីមាសទី៤?

| | | | | | | |
|---|---|---|---|---|---|---|
| | វិញ ដោយមានការកំណត់អំពីលក្ខខណ្ឌការងារយ៉ាងជាក់លាក់។ | | | | | |
| ១២.បញ្ច្រាប យេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រី | ១-ផ្អែកតាមលទ្ធផលសវនកម្មយេនឌ័របញ្ចូលសកម្មភាពជាក់លាក់ ដែលត្រូវអនុវត្តដោយស្ថាប័នអនុវត្តផអព | ត្រី.ទី២ | 😐 | អនុ.ទី១ | អនុវត្តបានសម្រេច | |
| | ២-លទ្ធផលសវនកម្មយេនឌ័រត្រូវបានប្រើសម្រាប់ការរៀបចំតាក់តែងផអពដំណាក់កាលបន្ទាប់ | ត្រី.ទី២ | ☺ | អនុ.ទី១ | អនុវត្តបានសម្រេច | |
| ១៣. រៀបចំ ផអព ដំណាក់កាលបន្ទាប់ | ១-លក្ខខណ្ឌការងារសម្រាប់ការរៀបចំតាក់តែង ផអព | ត្រី.ទី១ | ☺ | អនុ.ទី១ | អនុវត្តបានសម្រេច | |
| | ២- សេចក្តីព្រាងលើកទី១ បញ្ចប់ក្នុងខែឧសភា ឆ្នាំ២០១៤ | ត្រី.ទី២ | 😐 | អនុ.ទី១ | មានភាពមិនស៊ីសង្វាក់គ្នារវាង ក្រុមទីប្រឹក្សា និងលេខាធិការដ្ឋាន | គួរពិចារណាជម្រុញការអនុវត្តឱ្យ បានលឿនតាមពេលវេលាគ្រោង។ |
| | ៣- ការសិក្សាវាយតម្លៃរួមគ្នា (នៅក្នុងខែកក្កដា ឆ្នាំ២០១៤) | ត្រី.ទី៣ | ⚐ | អនុ.ទី១ | អាចមិនសម្រេចតាម ផែនការ ប្រសិនបើភាពមិនស៊ីសង្វាក់គ្នានៅតែបន្ត | |
| | ៤-សេចក្តីព្រាងចុងក្រោយ បានរៀបចំបញ្ចប់ (ក្នុងខែកញ្ញាឆ្នាំ២០១៤) | ត្រី.ទី៣ | ⚐ | អនុ.ទី១ | អាចមិនសម្រេចតាម ផែនការ ប្រសិនបើភាពមិនស៊ីសង្វាក់គ្នានៅតែបន្ត | |

សញ្ញាសំគាល់៖ ☺ = បានអនុវត្តតាមផែនការគ្រោង ☹ =មិនបានអនុវត្ត 😐 =អនុវត្តបានខ្លះ កំពុងប្រឹងប្រែងបន្ត ⚐ =អាទិភាពក្នុងត្រីមាសបន្ទាប់ ?= អាចអនុវត្តបានឬទេ ក្នុងត្រីមាសទី៤?

# បញ្ហានិងសំណូមពរនានារបស់ថ្នាក់ក្រោមជាតិ

| បញ្ហាប្រឈម | សំណូមពរ |
|---|---|
| ភាពយឺតយ៉ាវក្នុងការរៀបចំសេចក្តីសម្រេចរួម បានធ្វើឱ្យការអនុវត្តសកម្មភាព៦ខែដើមឆ្នាំ ក៏យឺតដែរ ។ | ថ្នាក់ជាតិ ជួយជម្រុញការរៀបចំនិងអនុម័តសេចក្តីសម្រេចរួមឱ្យទាន់ពេលវេលាយ៉ាងយូរបំផុតត្រឹមចុងខែមករា ។ **(ភារកិច្ចៈ អង្គភាពគ្រប់គ្រងនិងគាំទ្រកម្មវិធី)**<br>-ថ្នាក់ខេត្តត្រូវពិនិត្យឡើងវិញគ្រប់សកម្មភាពទាំងអស់ និងកត់ត្រាយោបល់អំពីមូលហេតុ ដែលមិនអាចអនុវត្តបាន ទៅក្នុងNAD មុនពេលធ្វើវិសោធនកម្មសេចក្តីសម្រេចរួម ។ |
| សកម្មភាពថ្នាក់ខេត្ត អាចអនុវត្តបានអាស្រ័យលើសកម្មភាពថ្នាក់ជាតិ ។ ហេតុនេះសកម្មភាពមួយ ចំនួន ដែលយឺត គឺដោយសាររង់ចាំថ្នាក់ជាតិ ។ | ស្នើលេខាធិការដ្ឋាន ជួយជម្រុញ គ្រប់អនុកម្មវិធីពាក់ព័ន្ធ ឱ្យអនុវត្តសកម្មភាព បណ្តុះបណ្តាល ឱ្យបានទាន់ពេលវេលាគ្រោងក្នុងផែនការ ។ |
| មានភាពមិនច្បាស់លាស់ ក្នុងការអនុវត្តរបស់ក្រុមងការងារគណនេយ្យភាពខេត្ត ដូចជាការគាំទ្រថវិកា និងនីតិវិធី ។ល ។ | ស្នើថ្នាក់ជាតិ **(អនុកម្មវិធីទី២)** ធ្វើការណែនាំឱ្យបានច្បាស់លាស់ អំពីកិច្ចដំណើរការរបស់ក្រុមការងារគណនេយ្យភាពខេត្ត ក្នុងរចនាសម្ព័ន្ធថ្មី រួមទាំងការគាំទ្រថវិកា ព្រមទាំងជនបង្គោលសម្រាប់ទំនាក់ទំនងនៅថ្នាក់ជាតិ ។ |
| - មធ្យោបាយអនុវត្តគម្រោងចាស់ៗ និងការស្នើ មិនត្រូវបានឆ្លើយតប (រថយន្ត ម៉ូតូ កុំព្យូទ័រ ម៉ាស៊ីនហ្វូតូ ម៉ាស៊ីនបញ្ចាំងស្លាយ...) ។ សម្រាប់បុគ្គលិកសម្របសម្រួលក្រុមប្រឹក្សា<br>- លទ្ធកម្មកង់ឡានមិនបានធ្វើប្រតិភូកម្មទៅ ថ្នាក់ក្រោមជាតិ (ដំណើរការមិនលក្ខណៈងាយស្រួល) ។ | - ស្នើសុំការគាំទ្របន្ថែម ការជួសជុល ការថែរក្សា និងលុបចោលពីបញ្ជីសារពើភណ្ឌ ។<br>- ស្នើសុំកែសម្រួលថវិកាសម្រាប់លទ្ធកម្មសម្ភារៈ ។<br>- ស្នើសុំ ផ្តល់លទ្ធភាពឱ្យខេត្តអនុវត្តលទ្ធកម្មតូចតាចខ្លះផង (Computer, Printer, etc.) ។<br>**(ភារកិច្ចៈ អង្គភាពរដ្ឋបាលនិងហិរញ្ញវត្ថុ)** |
| សមត្ថភាពនៅថ្នាក់ក្រុង ស្រុកក្នុងការអនុវត្ត ការគ្រប់គ្រងផសថ នៅមានកម្រិត | ស្នើសុំ ផ្តល់ការគាំទ្រធនធានមនុស្សដល់ថ្នាក់ស្រុក រួមទាំងការអភិវឌ្ឍបន្ថែម ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ ។ |
| សូចនាករក្នុង NAD ខ្លះហាក់មិនសូវស៊ីសង្វាក់គ្នាជាមួយនឹងសកម្មភាពដែលមាននៅក្នុងNAD | ស្នើថ្នាក់ជាតិពិនិត្យនិងរៀបចំសូចនាករ សម្រាប់សកម្មភាពក្នុង NAD ឡើងវិញ ។ **(ភារកិច្ចៈ អង្គភាពM&EI)** |
| នៅថ្នាក់ជាតិ ពុំមានព័ត៌មានអំពីជនបង្គោលទទួលបន្ទុកគាំទ្រ PID, District Finance, CS Accountability | លេខាធិការដ្ឋានគ.ជ.អ.ប ជួយផ្តល់បញ្ជីឈ្មោះ ជនបង្គោលទទួលបន្ទុកគាំទ្របច្ចេកទេស នៅថ្នាក់ជាតិ ។ |
| លិខិតស្នាមដែលផ្ញើមកពីខេត្ត ហាក់មានការយឺតយ៉ាវជាខ្លាំងទំរាំមានការឆ្លើយតប ឬធ្វើសកម្មភាព | ផ្នែករដ្ឋបាល និងជំនួយការឯកឧត្តម អនុប្រធានប្រតិបត្តិ គួរជួយតាមដានលិខិត ដែលផ្ញើមកពីតាមបណ្តាខេត្ត ។ |
| គ្មានការធានារ៉ាប់រងសុខភាព ដូចចែងក្នុងលក្ខខណ្ឌកិច្ចសន្យា | សូមជួយជម្រុញកិច្ចធានារ៉ាប់រងសុខភាពបានឆាប់រហ័ស |

**ករណីពិសេសសម្រាប់ខេត្តត្បូងឃ្មុំ**

- ស្នើសុំការគាំទ្រការរៀបចំសិក្ខាសាលាតម្រង់ទិស សម្រាប់ក្រុមប្រឹក្សានិងគណៈអភិបាល ទីចាត់ការទាំងអស់ ។
- ស្នើសុំការគាំទ្រ កសាងប្រព័ន្ធទំនាក់ទំនងព័ត៌មានវិទ្យា Internet, email ។